# អារម្ភបទ

*ជីវិត ដែលត្រូវបិទដោយរបាំង វាំងដោយវាំងននៈ កាលបើរបាំងរបេះ វាំងននបើក ក៏ត្រូវតែរស់រវើក ទៅដោយ ការ ស្រមើ ស្រមៃ ទៅរកសេចក្ដីថ្លៃថ្នូរ ដែលពោរពេញ ទៅដោយ សភាព អាប់អួ គួរឲ្យអាក់អន់ស្រពន់ចិត្ត ត្បិតការពិតនៃសេចក្ដី សុចរិត យុត្តិធម៌ សុចត្រង់ នៅតែស្រយង់ស្រយុតរន្ធត់ប្រាណ ព្រោះត្រូវ បានរំខាន ដោយពួក ខ្មាំង ប្រឆាំងនឹងជាតិខ្មែរ ។*

*តើ សភាពការណ៍ យ៉ាងណាខ្លះទៅ នឹងតម្រូវយកមក លាត ត្រដាង សំអាង បញ្ចាំង និងបញ្ជាក់ ក្នុងពេលបន្ត បន្ទាប់ទៅនេះ?*

*ចម្លើយបំភ្លែក នឹងជ្រៀតជ្រែក តាមតំណក់ទឹកភ្នែក សម្រែក ប្រេត និង សម្រេក ជីវិត-សម្រិតគម្លានដែលមាន នៅក្នុង* **ទាំងនៃជីវិត ។**

១.-តំណក់ទឹកភ្នែក

២.-សម្រែកប្រេត

៣.-សម្រេកជីវិត-សម្រិតគម្លាន

*ដើម្បី សម្របសម្រួល បបួលខ្មែរ បំបែរភាពពុំស្រួល រមួល គ្រិច ពន្និចខ្មែរ ឲ្យប្រែជា ភាពស្រួលស្រណុកសុខសប្បាយឡើងវិញ ដោយវៀរចាកចេញ ពីសម្រក់ទឹក ភ្នែក សម្រែកថ្ងូរ អាសូរខ្មែរ រ៉ៃតែក្នុងរន្ធត្រចៀក៖*

**ឆូចគិម ស្នួតិ**

វិស្វករវង្គតបុរី

## ១.-តំណក់ទឹកភ្នែក

នៅឆ្នាំ១៩៣៨ ទារកគិមសួគិ ស្រែកយំផ្អា ប្រវេប្រវា ចាប់កំណើត នៅភូមិវត្ត សង្កែ ស្រុកសង្កែ ខេត្តបាត់ដំបង ក្នុងគ្រួសារក្រខ្សត់ អត់អំណាចកាចសាហាវ ។

គូព្រេងមិនព្រាត់ ដ៏កម្សត់នេះ ជាអ្នកអារីសកូន គឺមានកូនច្រើនផងដែរ ប៉ុន្តែ ថែរក្សាមិនគង់ គ្រាន់តែកើតមកហើយ រស់នៅមិនបានយូរប៉ុន្មាន ចេះតែស្លាប់ ឬគ្រាន់តែកើតមកភ្លាម ក៏ស្លាប់ភ្លាមទៅ ។ ហេតុនេះហើយបានជា កុមារគិមសួគិត្រូវ ឪពុកធំ ម្តាយធំ ឈ្មោះឈាម-យិន ដែលគ្មានកូនសោះ សុំយកទៅធ្វើជាកូនចិញ្ចឹម នៅ ឯភូមិអូរស្រឡៅ ចម្ងាយប្រមាណ ១១ គីឡូម៉ែត្រ ពីទីរួមខេត្តបាត់ដំបង ។

អាយុបាន ៤ ឆ្នាំ កុមារគិមសួគិត្រូវជិះក ឪពុកមា ឈ្មោះម៉ាន់ ដែលត្រូវជាប្តីនៃម្តាយមីង ឈ្មោះអ៊ិត ទៅកាន់ភូមិអូរស្រឡៅ ទុកឲ្យម្តាយឈរទ្រឹងនៅមើលផ្លូវកូន លុះផុត កន្ទុយភ្នែក និងលែងឮសម្រែក ដោយតំណក់ទឹកភ្នែករលេងរលោង !

អូរស្រឡៅ ជាភូមិមួយដ៏តូចប្រឡឹង លាតសន្ធឹងតាមបណ្តោយទាំងសង្ខាងផ្លូវដែក ដែលភ្ជាប់គមនាគមន៍ ពីភ្នំពេញទៅខេត្តបាត់ដំបង រួចរំលងរហូតដល់ព្រំដែនកម្ពុជា-ថៃ ។

ជារៀងរាល់ថ្ងៃ នៅពេលព្រឹកឮសន្ធឹកលាន់សន្ធាប់ ពីក្បាលម៉ាស៊ីនដុតឱស ហៅថាយន្តចំហាយ ប្រាយប្រាប់ តាមដោយសញ្ញាកញ្ចែយ៉ាងវែង “ វេត! វ៉ូត! វេត! វ៉ូត! ” ថានឹងចូលចតនៅជំណាក់អូរស្រឡៅ ហើយនឹងនាំទៅនូវអ្នកដែលត្រូវធ្វើដំណើរបន្ត ។

ជំណាក់ ឬរ៉ា ឬថាស្ថានីយអូរស្រឡៅជាបង្គោលដៅបែង ចែក ភូមិអូរស្រឡៅ ខាងលិច និងភូមិអូរស្រឡៅខាងកើតស្ថានីយ ។

ឪពុកខ្ញុំ ឈ្មោះម៉ៃ ជាកូនកំព្រាម្តាយតាំងពីតូច ។ ជីតាខ្ញុំ ឈ្មោះឃឹម ជាអតីតនាម៉ឺន សម័យលោកម្ចាស់បាត់តាំងនៅម្តុំត្រែងសំឡូត ក្នុងខេត្តបាត់ដំបង ។ ជីដូនខ្ញុំ ឈ្មោះមឿន ។ យាយមឿន មានបងប្អូន ៦ នាក់ តាមលំដាប់អាយុ ដូចតទៅ រស់នៅឯភូមិភ្នំសំពៅ៖

១.-យាយ មៀន

២.-យាយ យ៉ម

៣.-យាយ វ៉ាន

៤.-តា ឡូត

៥.-យាយ គីន

៦.- តា ព្រឹល

ម្ដាយខ្ញុំ ឈ្មោះ អ៊ាម ជាកូន កាត់ ចិន-ខ្មែរ ។ ជីតា ខ្ញុំ ឈ្មោះ ខាច ជាជាតិ ចិន ទាជីវ ជីដូនខ្ញុំ ជាខ្មែរ អង្គរ ។

ម្ដាយខ្ញុំ មានបងប្អូនស្រី៥នាក់ តាមលំដាប់អាយុ ដូចតទៅ ៖

១.- យិន

២.- អ៊ាម

៣.- អ៊ិត

៤.- លាង

៥.- លិន

ក្រៅ ពីឪពុកម្ដាយ និងបងប្អូន បង្កើតខ្ញុំ ដែល រស់នៅ ឯវត្តសង្កែ និង មីង មា របស់ ឪពុកខ្ញុំ ដែលរស់នៅឯភ្នំសំពៅ អ៊ុំប្រុស អ៊ុំស្រី មា មីង ព្រមទាំងបងប្អូនជីដូនមួយរបស់ខ្ញុំ ទាំងអស់ ត្រូវរស់ឯ ភូមិ អូរស្រឡៅ ខាងកើតវ៉ា នៅលើកោះតូចមួយ ដែលមាន អូរព័ទ្ធ ជុំវិញ ។

ភូមិនេះមាន១៣គ្រួសាររស់នៅ ។ គ្រួសារនិមួយៗមាន ឈ្មោះ ប្ដី-ប្រពន្ធ ប្រព័ន្ធ ជាមួយគ្នា ដូចតទៅ ៖

១.- ណម-យិន

២.- ម៉ាន់-អ៊ិត

៣.- អេ-គា

៤.- យឿម-មៀន (មៀនជា ប្អូនស្រី របស់ឪពុកបិញ្ជីមខ្ញុំ)

៥.- ថន-ឡូន (ឡូនជា បងស្រី របស់ឪពុកបិញ្ជីមខ្ញុំ)

៦.- ស៊ិន-ចាន់

៧.- សយ-ស៊ន (សយ ជា កូនប្រុស ស៊ិន-ចាន់)

៨.-អម-សឿម (សឿម ជាកូនស្រី មេឃុំស្រី-រឿម)

៩.-ប្រប-ឈាង

១០.-ឌួង-លិន

១១.-រិន-ឡេង (រិន ជាបងប្រុសឪពុកបិញ្ចឹមខ្ញុំ)

១២.-ម្ហូ-អោន (បងប្អូនជីដូនមួយ ម្តាយខ្ញុំ មកពីអង្គរ)

១៣.-ឆេង (ប្អូនប្រុស យាយរឿម កម្ទោះបាស់)

មាន នៅសល់ដី ៤ កន្លែងក្នុងភូមិ កោះ ដែលម្ចាស់រស់នៅ ឯភូមិ ត្រើយម្ខាងខាងជើងអូរ និង២កន្លែង ដែលម្ចាស់១គ្រួ នៅឯវត្តគរ ១គ្រួទៀតរស់នៅ ឯត្រើម្ខាងខាងកើតអូរ ៖

១.ដីរបស់ មាម៉ុច

២.-ដីរបស់មាចឿន

៣.-ដីរបស់មាសន

៤.-ដីរបស់ មានួម

៥.-ដីរបស់ឡើម-សយ (សយជាកូនស្រី តាស្រី-យាយរឿម គាត់ទិញដីពីតានុច ក្រោយពីយាយឆ្លុង បានធ្វើមរណកាទៅ )

៦.-ដីរបស់ឡែម-សួម (សួមជាកូនស្រីតាស្រី-យាយរឿម)

រួមសេចក្តីអ្នកម្ចាស់ដីនៅភូមិកោះវត្តបែង មាន៤គ្រួគឺ គ្រួសារ តានុច តាស្រី (មេឃុំអូរជំបង) តាស៊ិន និងតាអេ ។

តាស៊ិន ជាព្រឹទ្ធាចារ្យ ម្នាក់ មានបំណេះចេះដឹងជាងគេ នៅ ក្នុងភូមិ បន្ទាប់ពីតាស្រី ដែលគាត់រវល់តែធ្វើមេឃុំ នៅឯអូរជំបង ។ តានុចទំនងជាអ្នកបាប់ដី និងរុនរានទន្រ្ទានព្រៃមុនគេបង្អស់ ។

តាស៊ិន គាត់ឧស្សាហ៍ មក លេងផ្ទះ ឪពុក ម្តាយ បិញ្ចឹមខ្ញុំ សឹង រៀង រាល់ យប់ នៅពេលខែភ្លឺម្តងៗ ហើយគាត់តែងនិទានរឿងឲ្យឪពុកម្តាយបិញ្ចឹមខ្ញុំ និងខ្ញុំស្តាប់ ។

រឿងដើមកំណើតរន្ទះ គូរវាសជាភ្លេកបន្ទោរនៅលើមេឃ ក៏ត្រូវបានវែកញែកដោយសារ តាស៊ិន ដូចតទៅ ៖

# រឿងកាំរន្ទះ

# ៤៤

កាលពីព្រេងនាយ មានបិសាចមួយ ឈ្មោះរាមាសូរ និងនាងអារក្សទេវី ឈ្មោះមេខលា ។ អ្នកទាំងពីរ បាននៅបំរើមហាឫសីដ៏មានឫទ្ធិម្នាក់ ដើម្បីរៀនវិជ្ជាមន្តអាគមគាថា ។ បិសាចនិងនាងអារក្សទេវី បានខំរៀនប្រណាំងប្រជែងគ្នា ដើម្បីបំពេញចិត្តគ្រូរៀងខ្លួន ហើយអ្នកទាំងពីរ ប្រកបដោយបញ្ញាវៃក្រៃលែងដូចគ្នា ។ តាបសក៏ស្រឡាញ់អ្នកទាំងពីរនោះស្មើគ្នា ។ កាលបើតាបសបានបង្រៀនសិស្សលោកចប់សព្វគ្រប់មុខវិជ្ជាហើយ លោកក៏ចង់ល្បងវិជ្ជាសិស្សមើល ថាតើនរណាបុិនប្រសប់ជាងគេ ។ ទើបលោកនិយាយទៅកាន់សិស្សថា ៖ “ បើអ្នកណាមួយ យកកែវមួយមានទឹកសន្សើម ពេញមកឲ្យខ្ញុំបាន នោះខ្ញុំនឹងធ្វើទឹកនោះ ឲ្យក្លាយទៅជាកែវមនោហរា ហើយដោយគុណភាពនៃរតនវត្ថុនោះ អ្នកម្ចាស់កែវ អាចប្រាថ្នាធ្វើអ្វី ឬចង់បានអ្វី បេះតែបានសំរេចទាំងអស់ ”។

រាមាសូរ ក៏យកកែវទឹកមួយ ទៅត្រងទឹកសន្សើមដែលទើរ នៅស្លឹកឈើនិងស្មៅផ្សេងៗ ។ វាបានខំព្យាយាម ធ្វើដូច្នេះជាច្រើនព្រឹក ប៉ុន្តែឥតបានលទ្ធផលល្អសោះ ។

ចំណែកឯនាងមេខលា ដែលជាស្រីចេះគិតវែងឆ្ងាយ ក៏រើសយកបណ្តូលឈើមួយ យ៉ាងទន់ស្តោតៗ ហើយយកទៅដាក់ផ្តិតលើទឹកសន្សើម ដែលដក់លើស្លឹកឈើនិងលើស្មៅ ទាល់តែដុំឈើនោះដក់ទឹកនៅពេញទាំងអស់ ។ បន្ទាប់មក នាងអារក្សទេវីបានយកដុំឈើនោះ ទៅប្របាច់ទឹកដាក់ក្នុងកែវ ។ អាស្រ័យដោយហេតុដូច្នេះ នាងក៏រកទឹកសន្សើមដាក់កែវបានពេញ ហើយក៏យកកែវនោះទៅជូនមហាតាបស ។ ហេតុដូច្នេះ បានជានាងអារក្សទេវី ត្រូវបានតាបសសំគាល់ថា បុិនប្រសប់ជាងបិសាច ។

តាបសជប់ទឹកសន្សើមនោះឲ្យកើតទៅជាកែវ ហើយប្រគល់ទៅឲ្យនាងមេខលា ដោយប្រាប់ថា ៖ “ កែវនេះមានគុណភាពខ្លាំងពូកែណាស់ បើអ្នកមានបំណងអ្វីមួយ គ្រាន់តែលើកកែវនេះគ្រវីឡើង នោះមួយរំពេច សេចក្តីប្រាថ្នារបស់អ្នកនឹងបានសំរេច

ក្ងាម មួយទៀត ដោយគុណភាពនៃកែវនេះ អ្នកអាចហោះ កាត់អាកាស កប់ពពក ជ្រក អាចម៍ជន្ទេន ទៅកាន់កន្លែងណា ក៏បានទាំងអស់ ។

នាងអារក្ខទេវី ក៏ទទួលយកកែវនោះមក លើកត្រវីឡើងលើ ស្រាប់តែហោះវឹង ទៅលើមេឃ តម្រង់ទៅមហាសាគរ ។

ចំណែកឯរាមាសូរ អាស្រ័យដោយការព្យាយាមដ៏យូរ ក៏រកទឹកសន្សើមដាក់បាន ពេញកែវ ហើយយកទៅថ្វាយ មហាឫសី ។ ពោលថា ៖ «ចៅឯងយករបស់នេះ មកយឺត យូរពេក ហួសពេល តាត្រូវការ ឥឡូវតាបានឲ្យរតនវត្ថុនោះ ទៅនាងមេខលាទៅហើយ មន្តអាគមតាថារបស់តា អាចជប់វត្ថុបែបនេះ កើតបានតែមួយដងគត់ទេ” ។

កាលបើ ឮ មហាឫសីតាបស ថាដូច្នេះ រាមាសូរ ក៏កើត សេចក្តី ទោមនស្ស ពន់ ប្រមាណ ហើយស្រែកយំអណ្តឺត អណ្តូត យ៉ាងខ្លាំង ។

ដើម្បីលួងចិត្តបិសាច តាបសក៏ប្រាប់ថា ៖ “ចូរ ចៅ កុំកើតទុក្ខខ្លាំងពេក ចាំតាឲ្យ ពូថៅមួយ ពូថៅនេះ អ្នក អាចយកទៅ ឈ្នោះ ដណ្តើម យកកែវ ពី នាងអារក្ខ ទេវី មេខលា បាន នាងមេខលានេះ ចូលចិត្តហោះហើរ លេងនៅ លើអាកាស ដើម្បីមុជទឹក ភ្លៀង នៅ ពេលភ្លៀងម្តងៗ ចូរ អ្នកបោល ពូថៅនេះទៅលើវា វា នឹង បោះ បោលកែវ ដ៏មានតម្លៃនោះ ប៉ុន្តែ បើ នៅ ពេល ប្រយុទ្ធគ្នានោះ ចៅឯងឃើញវាលើកកែវឡើងត្រវី ចូរ ចៅឯងបិទភ្នែកក្ងាម មុននឹងបោលពូថៅ ទៅលើវា ”។

កាលបើរាមាសូរ បានពូថៅ មកកាន់ នៅនឹងដៃហើយ វា ហោះ ស្វះស្វែង រកនាង មេខលា ដើម្បីដណ្តើមកែវ មនោហ៍រា ប៉ុន្តែកាល បើឃើញនាង កាលណា នាងក៏យល់ ក្ងាមឃើញថា បិសាចនេះ ប្រាកដជាមានបំណងធ្វើអាក្រក់មកលើនាងពុំខាន ទើបនាង លើកកែវត្រវីឡើងហោះទៅលើអាកាស វេហាស៍ខ្ពស់ក្រៃលែង ។

កាលបើក្រឡេកឃើញពន្លឺចាំងនៃកែវមានសិល្ប៍ក្ងាម បិសាច ក៏បិទភ្នែក វាជិត រួចគ្រវែងអាវុធវាទៅ ។

អាវុធនោះបានហោះយ៉ាងលឿន ឮសូរសម្បើមក្រៃលែង ប៉ុន្តែ ឥតត្រូវនាងអារក្ខ ទេវីទេ ។

ចាប់តាំងពីពេលនោះមក ទើបនៅពេលមានភ្លៀងផ្គរ គេ ឃើញ បាំងពន្លឺកែវ ហើយ ឮសូរសំឡេង យ៉ាងខ្លាំងនៃអាវុធនោះ ។

អាស្រ័យហេតុនេះហើយ បានជាក្នុងភាសាខ្មែរ ហើយឲ្យ ឈ្មោះ ដុំថ្ម ទាំងឡាយ ណា ដែលឃើញមាន រាងដូច ផ្លែពូថៅ ឬ ចប កាប់ ក្បាលស្រួច ឬ ដូចកាំបិតថា “កាំរន្ទះ” ហើយ សន្មតរបស់ទាំងនោះថា ជាព្រួញរបស់យក្សបាញ់នៅលើមេឃ ធ្លាក់មកដី ៕៚

**តំណក់ទឹកភ្លៀង**

**៤៤**

រៀងរាល់ដើមឆ្នាំ ផ្គរលាន់ គគ្រឹក សន្ធឹកគគ្រាំ គ្រហឹម គគ្រេង សំដែងភាពក្រេវក្រោធ និងសភាពគ្រៀមក្រោះ គួរឲ្យស្រណោះដល់ដីបែកក្រហែង ផ្សែងធូលីហុយទ្រលោម នាំឲ្យទ្រោមចិត្ត អាណិត អនាថ ដល់ធម្មជាតិ ដែលរងាទ ឃ្លាត បាកសម្រស់ សម្ផស្ស និងសោភ័ណភាព ។

ភ្លេកបន្ទោរ ធូតបន្ទាត់ ធ្លាត់ឆ្វែង សំញ៉ែញឫទ្ធី មេឃមិរ ស្រទុំ ពពកជុំជិត បិទបាំងសែងសុរិយា ភ្លៀងបង្អុរធ្លាក់ជោកជាំដី ។

អ្នកស្រុកប្រុស–ស្រី ទទួលអបអរសាទរ នឹងបានទឹក ធ្វើស្រែ ចម្ការ ច្បារដំណាំ ប្រចាំជីវិត ។

ទឹកហូរប្រោះ ជ្រែកសព្វក្រហែង ក្រហេងក្រហូង ក្រហួង ក្រហត កន្ទុក កន្ទៀត ជ្រៀតសព្វទីទំនាប ជ្រាបសព្វទីកន្លែង ។

ទឹកហូរបំពេញស្រែ បំពេប្រឡាយ បំពាយសម្រាមសម្រាស់ បំប៉នស្រះ បំពាស អណ្ដូង បំប៉ោងត្រពាំង បឹងបួ បង្អូរព្រែក ជ្រែកប្រោះចូលជ្រោះ រំដោះជងអូរ បង្ហូរ ចូលស្ទឹង សំឡឹងទន្លេ រួចក៏វេរមិញ ត្របាញ់ទៅសមុទ្រ ដោយបាននាំធាតុសុទ្ធ និង ធាតុមិនសុទ្ធ ទៅជាមួយផង ទំនងជាពុំអាចវិលត្រឡប់វិញ ដែលពុំមានអ្វីនឹងនាំ ឲ្យបំណោញដល់ប្រភពកំណើតដើម ជាដង្ហើមរស់ ដោយអស់ន័យ គ្មានអ្វីជាទិសឆ្ស៊ឹម

ជាទីគួរឲ្យញញឹមញញែម ប្រិមប្រិយ តាមសេចក្តីប្រាថ្នា សប្បាយនឹងថែទាំគាំទ្រ កសាងនិងការពារ ជាតិ សាសនា ព្រះមហាក្សត្រ និងជីវិតផងខ្លួន ឲ្យមានព្រលឹង ព្រលះ ឈ្នះអស់មារសត្រូវ ហើយនឹងរស់នៅដោយសេចក្តីថ្លៃថ្នូរ ជាមួយនឹងអ្នកជិតខាងដោយមានសំណាងលើកស្ទួយ កេរ្តិ៍ឈ្មោះកិត្តិយស ដល់ពិភពលោក ដោយពុំប្របល់ប្របូកប្រឡូកប្រឡំ បន្ទំវាតទី ។

តែបើក្នុងពេលឥឡូវ ព្រះមហាក្សត្រ ត្រូវបានក្លាយជាព្រះមហាខ្សត់ គឺអត់តាំងពីអំណាច នយោបាយ មធ្យោបាយ និង ឧបាយ ជា ពិសេស អរិយនយោបាយ អរិយមធ្យោបាយ និងអរិយឧបាយ ដែលជានយោបាយប្រសើរដែលជាមធ្យោបាយប្រសើរដែលជាឧបាយប្រសើរ ប្រកបដោយដំណើរ ដំណោះស្រាយ ការ ស្តាបនា និងដំណោះសារការពារជាតិ សាសនា និងព្រះមហាក្សត្រ យ៉ាងណាទៅ ?

ទឹកច្រើន លិចវាល រាលដល់ចុងព្រៃ គ្មានអ្វីនឹងទប់ទល់ ជាហេតុនាំឲ្យអកុសលផ្តល់ទឹកជំនន់ជាញឹកញាប់ ធ្វើឲ្យស្លាប់អស់ទាំងគោទាំងក្របី ដែលក្លាយទៅជាចំណីត្រីហែបហែលមកក្របែលធី ត្រៀបត្រា រួចហ្វូងមច្ឆា ក៏នឹងក្លាយទៅជាអាហារនៃមនុស្សនិងសត្វ ដែលស្វែងស្វះស្វាត់ ស្កាត់មករកចំណី ប្រចាំជីវិត ។

កាលបើគ្មានភ្លៀង ទៀងតែគ្មានទឹក!
កាលបើធ្លាក់ភ្លៀង យ៉ាងសែនសន្ធាប់សន្ធឹក

... ក៏ត្រឡប់ទៅជាលិចលង់!

... ហើយអ្នកស្រុកក៏មិនចេះថែរក្សាទឹកឲ្យគង់ ទើបបានជាអ្នកស្រុក ហាក់ដូចជាឆោតល្ងង់ ជួនក៏ទៅអារាធនាព្រះសង្ឃសូត្រធម៌សុំទឹកម្តងៗ ជួនក៏ទៅ អន្ទងចាប់ឆ្មាយកមកស្រោចទឹក គគ្រឹកគគ្រេង វាយភ្លេង វាយគង សំពងឃ្មោះ ពីព្រោះយល់ថាមកពីអំពើខុសឆ្គងរបស់ផងខ្លួន ដែលគាប់ជួននាំឲ្យខ្វះទឹកធ្វើស្រែ ។

សភាពប្រែប្រួលបបួលឲ្យអ្នកស្រែខ្វះ ដែលខ្វះស្រូវក៏សុខចិត្ត “ធ្វើមុខឆ្កែ ស្រែជម្រៅ” ទៅសុំខ្ចីបុលស្រូវគេ ដូចជាស្រូវថៅកែ ជាដើម យកមកហូបចុក បុកទំពារ ឬក៏ទុកបង្ការធ្វើពូជ សម្រាប់សាបព្រោះ ដាំដុះនៅឆ្នាំមុខ ។

ធ្វើមុខឆ្កែ គឺ ពិតជាគិតតែ ពីជជ្រកមមក ទៅមករកគេ ដោយឥតអៀនខ្មាស ព្រោះ ដោយកង្វះខាត ។

ស្រែជម្រៅ គឺ ស្រែដែលត្រូវទទួលទឹកច្រើន កើនលុះត្រាតែលិចស្រូវរលួយខូច អស់ ។ មានតែស្រូវវារ ឬស្រូវឡើងតាមទឹកទេ ដែលអាចដុះដាល រាលវាលគុម្ព នៅក្នុងស្រែជម្រៅបាន ហើយមានផ្ទវនឹងហុចផ្កាផ្លែ ។ ក៏ប៉ុន្តែផ្លែស្រូវវារនេះ ពុំមាន រសជាតិឆ្ងាញ់ពិសា ក្នុងការទទួលទាន ទាល់តែសោះ ។

រឿងដែលទាក់ទងនឹងពិធីសុំទឹកភ្លៀង ក៏ត្រូវបានបរិយាយបកស្រាយដោយលោក តាស៊ិន ដែរ ។

## រឿងបួងសួងសុំទឹកភ្លៀង

ទឹកភ្លៀង ជាវត្ថុធាតុមួយដ៏វិសេស ទោះបីរុក្ខជាតិក្តី សត្វក្តី មនុស្សក្តី សឹង អាស្រ័យទឹកភ្លៀងដើម្បីរស់ទាំងអស់ ។ អស់រដូវប្រាំងទាំងមូល ដែលនាយឧទ្យាន ខំ ស្រោចស្រពដំណាំដោយទឹក តែការបំរើនលូតលាស់ដំណាំនោះ មិនស្មើនឹងបានទឹក ភ្លៀងស្រោចស្រពមួយដងទេ ។ ដូច្នេះក្នុងគ្រា ឬឆ្នាំណាដែលខ្វះទឹកភ្លៀង រមែងមាន ហេតុភ័យ បណ្តាលឡើងពីរយ៉ាងគឺ ភ័យអំពីការអត់ឃ្លានម្យ៉ាង ភ័យអំពីរោគាព្យាធិ ម្យ៉ាង ។ ភ័យន្តរាយដ៏ធំទាំងពីរយ៉ាងនេះឯងហើយ ជាកត្តាឲ្យទំនៀមសុំទឹកភ្លៀង ទៅជា ទំនៀមមួយយ៉ាងសំខាន់ ដែលខ្មែរយើងរក្សាទុក បានឋិតថេរតមក ។ ការរាំងភ្លៀង តែងតែធ្វើឲ្យសត្វលោករងទុក្ខវេទនាខ្លាំងបំផុត ។

មានសេចក្តីដំណាលថា ក្នុងកាលកន្លងទៅហើយ ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង យោនយកកំណើតជាសត្វត្រីរ៉ស់ ស្ថិតនៅក្នុងស្រះមួយនាទស្សបុរី ។ កាលនោះ ក្នុងទស្សបុរី ទាំងមូល ពុំមានបង្អុរភ្លៀងចុះសោះ លុះរាំងរីសយូរៗទៅ ទឹកបឹងទឹកត្រពាំង ក៏រីង ហួតអស់ ។ ចំណែកស្រះដែលមានស្តេចត្រីរ៉ស់នៅនោះ ក៏រីងខះដែរ នៅសល់តែ ភក់ខាប់ៗ ពេលនោះពួកត្មាត កុក និងក្រសាទាំងឡាយ នាំគ្នាចុះចឹកត្រីក្នុងស្រះនោះស៊ី យ៉ាងរីករាយ ជារៀងរាល់ថ្ងៃ ។ ស្តេចត្រីរ៉ស់ ក៏បង្គាប់ឲ្យពួកត្រីទាំងឡាយ ឲ្យមុជចូល

ជ្រក លាក់ខ្លួនក្នុងភក់ យ៉ាងវេទនាណាស់ ។ ថ្ងៃមួយ ស្ដេចត្រីរ៉ស់ ជំនុំនឹងត្រីរង គ្រោះឯទៀតថា ៖ “ តាំងពីពួកយើងមកចាប់កំណើតជាត្រីនេះ មិនដែលធ្វើអ្វី បៀតបៀនសត្វណាម្ដងទេ មិនគួរឡើយ យើងមកទទួលការលំបាក យ៉ាងនេះសោះ” ។ គ្រានោះ ស្ដេច ត្រីរ៉ស់ តាំងអធិដ្ឋានបួងសួង នឹកដល់គុណ ព្រះរតនត្រ័យថា ៖ “សូមតេជះគុណ កែវទាំងបី ជាទីពឹង របស់សត្វលោក សូមព្រះអង្គជួយស្រោចស្រង់ យើងទាំងឡាយផង! ” ។

នៅពេលនោះ ក៏កើតហេតុអស្ចារ្យ គឺក្ដៅដល់ទៅអាសនាព្រះអម្រិន្ទាធិរាជ ។ បានជ្រាបហេតុអស្ចារ្យដូច្នេះ ព្រះឥន្ទ្រាធិរាជ ទ្រង់ត្រាស់ប្រើទេវបុត្ត មួយអង្គ ឲ្យបង្អុរភ្លៀងចុះមកសព្វទិសទី លិចទីទាបគ្មានសល់ ។ ស្ដេចត្រីរ៉ស់ ព្រមទាំងពពួកត្រីទាំងឡាយ បានសេចក្ដីសុខសប្បាយ តាំងពីពេលនោះមក ។

ដោយ មានរឿង អស្ចារ្យ យ៉ាងនេះឯងហើយ ទើប កាលណា មានការ រាំងបុស្ស អ្នកស្រុក តែងនាំគ្នា ធ្វើពិធី សុំទឹកភ្លៀង ដោយ មាន និមន្ដព្រះសង្ឃ សូធ្យធម៌ សុំតោរន្ឌោ មានធ្វើស្រះតូចមួយ ហើយ រកត្រីរ៉ស់ យកទៅ ដាក់ ឲ្យ ហែល ក្នុងទឹកនោះ រួច ធ្វើពិធី បួងសួងសុំទឹកភ្លៀងទៅ ៕៚

នៅក្នុងភូមិអូរស្រឡៅ ខាងកើត ព្រះវិហារវត្តបែង សំញែងដំបូល កំពូលជហ្វាជងក្ដារ យ៉ាងសង្ហារស្កឹមស្កៃ លេចផុតចុងព្រៃព្រឹក្សា ។

អ្នកភូមិអូរស្រឡៅ រមែងកក់ក្ដៅ នឹងបុណ្យទាន មានសទ្ធាជ្រះថ្លា គោរពបូជាព្រះពុទ្ធសាសនា យ៉ាងក្រៃលែង ។

នៅឆ្នាំ១៩៨៦ វត្តបែង សំបូរសប្បាយណាស់ ។ នៅពេលបុណ្យភ្ជុំ ម្ដងៗ អន្សមជ្រូក អន្សមចេក ត្រូវលោកយកមកផ្ញើរ ទាំងរានៗ ។

នៅលើដំបូលព្រះវិហារ សត្វព្រាបស្រែកថ្ងូរ ពុស្ងូរថា ៖

“ រាករូសរូ! រាករូសរូ! “ រួចក៏បន្ទោរឧច្ចារៈប្រេច ដាក់លើព្រះវិហារ និងនៅលើអ្វីៗ ដែលនៅក្បែរទីនោះ ។

នៅលើចុងអំពិល ខាងលិចព្រះវិហារ លលកតុក គន់ គូរ ដោយ ក្ដីប្រណែននិន្ទានឹងព្រាប ថាអាតុក ព្រោះព្រាបវាបាន ដេកស៊ី យ៉ាង សែន ស្រណុក នៅលើដំបូល ព្រះវិហារ ហើយចេះតែស្រែកថ្ងូរថា ៖ “ រាករូសរូ! ” មិនចេះឈប់ឈរ ឯចំណែក លលក ក៏

លាក់ខ្លួនពួនទុំជ្រកតែលើមែកឈើ ហាលភ្លៀង ហាលខ្យល់ ទាំងយប់ ទាំងថ្ងៃ ក៏ស្រែកយូរថា៖

រាករកគ្រូ! អាគុក!... រាករកគ្រូ! អាគុក! អាគុក!

សត្វគូកបន្តរពីក្នុងអូរខាងកើតវត្តថា៖ គូក! គូក!

លលកទ្រាំង យំទ្រោលពោលថា៖

គ្រូ! គោរោទិ៍! គ្រូ! គោរោទិ៍!

គោឈ្មោលស្រែករោទិ៍រកហ្ម ថា៖ ឱម ហ្ម! ឱម ហ្ម!

គោញី បន្តរថា៖ ហ្ម! ហ្ម! រួចក៏បោលទៅ ហើយគោឈ្មោល ក៏បោលតាមពីក្រោយ ដោយប្រកិត ។

ទៅជួបនឹងត្រដេវវិច នៅក្បែរព្រៃ គោញីសួរថាបេះធ្វើពេទ្យហ្ម ឬទេ? ដោយបញ្ចេញសំឡេងថា៖ ហ្ម! ហ្ម! ។

ត្រដេវវិចឆ្លើយតបទៅគោ ថា៖ តិច តួចទេវិច! តិច តួចទេវិច! រួចក៏បេះតែរត់និងហើរប្រិចៗ ទៅមុខ ដាហូរហែ ហាក់ដូចជាចង់ញ៉ែ គោឲ្យដេញតាមសួរ ...។

ត្រលេងត្រលោង ត្រលៀសសម្តីលេង ពីលើចុងក្រសាំងថា៖

ជាក៏លៀង! មិនជាក៏លៀង!... ជាក៏លៀង! មិនជាក៏លៀង!

រឹកសារិកា ស្រែកកោកកាក ថា៖ រកអារក្ស! រកអារក្ស!

ប៉ោលតោក ខោកសម្តីទម្លាយទ្រូងព្រៃ យ៉ាងក្រអៅថា៖

ប៉ោលតោក! ប៉ោលតោក!

ក្អែក ស្រែកប្អូល ថា៖ មក៏អាឡូវ! មក៏អាឡូវ!

តាវៅបញ្ចេញក្រអៅ ថា៖ តាវៅ! តាវៅ!

ទីទុយ ហុចតម្រុយបន្ទុយពាក្យថា៖ ទីទុយ! ទីទុយ!

ទោច ទទូចទាមទារ មុខងារ ថា៖ ទោច! ទោច! រួចក៏រាកនោមប្រូចទៅលើចចកដែលខកចិត្តត្បិតបង្ហរមាត់ចាំស្តាប់នៅក្រោមដើមឈើ ដោយស្រែកបន្ទីថា៖ ចុកចុកជួរ! ចុកចុកជួរ!

ហឹងហងបំពងសំឡេងថា៖ ឯង ហង! ឯង ហង! រំពងយ៉ាងទ្រហឹងអឺងកងពេញផ្ទៃបឹង ។

តិងតក់តក់ទ្រូងពុ៖ ក្រត! ក្រត! យ៉ាងក្រៀមក្រំ ។

*កង្កែបយំវ៉ែបៗ ថា៖* អែប! អែប! អញអោប! អញអោប! កូប! កូប! *កូករកគ្នីគ្នា ។*

*ក្អាត់ ក្អាកក្អាយ ក្អេងក្អាង ថា៖* កាត់! កាត់!

*ទា ទាញបុំងតោមក់បំរុង ដោយតម្ងើសម្ងេងក្បូរ បុងប្រមុះថា៖* កាប់! កាប់!

*តុកកែក្អកត្រហែមពីលើពិតានព្រះវិហារ ដោយបន្ទោរបង់បស្សាវៈ ដាក់លើក្បាលជីងចក់ ដែលកំពុងតែង៉ិកង៉ក់ ងីងើពុំដឹងជាធ្វើអ្វី ហើយបោលសម្ដីឲ្យប្រុងប្រយ័ត្ន ថា៖*

ប្រូច! ប្រូច!... ទឹកតែ! ទឹកតែ!

*ជីងចក់ ទទួលអនុមោទនាទឹកមូត្រ ថា៖* ចត់! ចត់!

*ព្រាប ឮសូរថា* ចត់! ចត់! *ក៏នឹកស្មានថា ថ្នាំដែលត្រូវ យកមកព្យាបាលរោគរាករូស គឺជាថ្នាំដែលចត់ ដូចជាទឹកតែជាដើម ។ ព្រាបក៏សន្និដ្ឋានថា ហេតុដូច្នេះហើយបានជាព្រះសង្ឃ លោកពុំដែលរាករូសដាក់កុដិសោះ ព្រោះលោកបានឆាន់ទឹកតែ តែរៀងរាល់ថ្ងៃ ។ ពីថ្ងៃនេះតទៅ អាត្មាអញបានរកឃើញថ្នាំរាកហើយ អាត្មាអញនឹងបានជាសះស្បើយ លែងរាករូសដាក់ព្រះវិហារ និងព្រះទៀតហើយ ។*

*គិតឃើញដូច្នោះ ថ្ងៃមួយនោះ នៅពេលដែលក្មេងវត្ត បានធុងតែពេញមួយខ្ទះត្នោតមិននៅ ព្រាបក៏ហើរសំយុងបំរុងនឹងបុះទៅក្រេបទឹកតែ ដើម្បីព្យាបាលជម្ងឺស្រាប់តែរអិលជើងភ្លាត់ធ្លាក់ខ្លួនបូលទៅខ្ទះ ត្រូវទឹកតែក្ដៅរលាកស្រុសស្លាប់ទៅ !*

*ពេលក្មេងវត្តត្រឡប់មកវិញ បានឃើញព្រាបស្លាប់ក្នុងខ្ទះ នាំឲ្យវិនាសដល់ភេសជ្ជៈរបស់ព្រះសង្ឃ ក៏កើតសេចក្ដីខឹងសម្បារនឹងព្រាប រួចក៏យកដំណឹងទៅជម្រាបពិតពុទ្ធដីកាព្រះចៅអធិការ ។*

*ព្រះចៅអធិការទ្រង់ខ្វាល់ រួចរាល់ក៏សង្រួមឥរិយាបថ សង្កត់ខន្តិ ប្រោសប្រណីដល់សត្វ ហើយក៏បញ្ញត្តិឲ្យព្រះសង្ឃឆាន់ទឹកត្រដាក់ជំនួសទឹកតែ នៅក្នុងថ្ងៃនោះ ។*

*ក្មេងវត្ត នៅតែចងគំនុំនឹងព្រាប ។ ពួកវាបាននាំគ្នាទៅយកព្រាបមកបោច ។ តែវាបោចពុំដាច់ ។ ពេលនោះ មាន់គក ទទះស្លាបរងាវ ហាក់ដូចជាចង់ស្រែកប្រាប់ក្មេងថា៖*

ស្រុសបីដងបោច! ស្រុសបីដងបោច!

*ក្មេងវត្ត ស្ទុះទៅដាំទឹកក្ដៅបន្ថែមយកមកស្រុសព្រាប តាមសម្រែកអាគក ។*

ថ្ងៃពីអាបែ ដែលត្រូវជាមាន់ភូមិផងរបងជាមួយនិងអាគក ពុំបានចាប់ភ្លឹកនឹកនាថាអាគក អាច នៅរស់រានមានជីវិតពីព្រោះតាំងតែពីបែកគ្នាមក បាត់ដំណឹងសូន្យ ។ ពីដើមធ្លាប់សាសងគ្នាព្រឹកល្ងាច តែចាប់តាំងពីអាគក ត្រូវបាន ម្ចាស់យកទៅបំបរបង់បោល ឲ្យទៅនៅវត្ត ដោយសារតែវាជល់ភ្នាល់ចាញ់គេ ។ តាមធម្មតា អាគកត្រូវតែម្ចាស់សម្លាប់បោល ក្នុងករណីដែលជល់ចាញ់គេនេះ ។ ក៏ប៉ុន្តែម្ចាស់អាគក នៅសល់ជាប់ធម៌មេត្តា ករុណា អនុគ្រោះ សន្តោស លោះលា...បានជាអាគក អាច នៅរស់រានមានជីវិត ដល់ថ្ងៃនេះ ។

អាបែ ឮតែសម្រែកអាគកថា “ស្រុសបីដងបោច! ស្រុសបីដងបោច!” ក៏ស្រែកសួរអាគកថាព្រះសង្ឃឆាន់មាន់ឬទេ?

អាគកឆ្លើយប្រាប់អាបែថា៖ ឱាតែក្អួច! ឱាតែក្អួច! ត្រលាស់ពាក្យថា ដូចតែគ្នា! ដូចតែគ្នា!

និយាយពីក្មេងវត្ត កាលបើបានស្រុសបោចព្រាបរួចហើយ ក៏ចាត់ចែងគ្នីគ្នាឲ្យទៅបេះជីរ ស្លឹកក្រូចសើច ជីករំដេងស្លឹកគ្រៃ គាស់ទំពាំង រកកញ្ឆា យកមកស្ងោរជ្រក់ព្រាប ឲ្យបានឆ្ងាញ់ពិសា ម្តង ។

ចាប់តាំងពីថ្ងៃនោះមក ក្មេងវត្តបាន ស្គាល់រសជាតិសាច់ព្រាប ថាឆ្ងាញ់មិនចាញ់សាច់មាន់ប៉ុន្មានទេ ហើយមានតែប្រសើរជាងផង ។ ហេតុនេះហើយ បានជាព្រាប ភិតភ័យ មកលាក់ខ្លួនបំពួនអាត្មា នៅតាមវត្តវ៉ាយ៉ាងដូច្នេះ ព្រោះថានៅក្នុងវត្តវ៉ា គ្មាននរណាហ៊ានមកបំពារបំពាន លើជីវិតសត្វទេ សូម្បីកណ្តុរ ក្រឡាត ជីងចក់ តុកកែ ឆ្កែ ឆ្មា ក្អែក បាប លលក ស្រមោច សង្អារ សត្វផងនានា... ក៏រស់ នៅយ៉ាងសុខសាន្ត...។

ដំណឹងសាច់ព្រាប ឆ្ងាញ់ ចាប់ល្បីល្បាញចេញពីក្មេងវត្ត ពី មាត់ មួយ ទៅមាត់មួយរហូតដល់ទៅកន្លែងលក់ម្ហូបអាហារ ជាហេតុបណ្តាលឲ្យព្រាបរលោះអស់ពាយ ពីក្នុងវត្ត។

ព្រះវិហារក៏ត្រូវថែរក្សាឱ្យបានស្អាតបាតបានមួយគ្រាដែរ!

កំប៉ុន្តែព្រះសង្ឃ លោកមិនចង់ឲ្យជីវិតនៃសត្វជាពិសេសជីវិតព្រាបបាត់បង់ កំព្រះសង្ឃ ដាក់បញ្ញត្តិ កុំឲ្យពុទ្ធសាសនិកជន សម្លាប់សត្វ ហើយ ដាក់វិន័យ តឹងតែងដល់ក្មេងវត្ត កុំឲ្យសម្លាប់សត្វ ជាពិសេស សម្លាប់សត្វព្រាប តែម្តង ។

លោកតាស៊ិន បានអធិប្បាយ រឿងព្រាបស្រែកថ្ងូរកគ្រូ ឬ " បក្សីលៀងអារក្ស " ដូចតទៅ៖

## រឿងបក្សីលៀងអារក្ស

## ៩៩៩

នេះនិងថ្ងៃថ្ងៃពីរឿងសត្វទាំងឡាយ កើតបលាបល ដោយសារ សត្វផងគ្នា មានជំងឺ ហើយដើរស្វែងរកមេមត់មកជួយមើល ។

កិរ: កាលនោះ មានសត្វព្រាប មួយមានទុក្ខ ដោយឆ្វេងទន្លេ មិនរួច ម៉្ងោះហើយ ព្រាបបេះតែថ្ងូរ រហ៊ឹះសុំឲ្យ គេជួយ ។ ត្រង់នេះហើយ ដែលនាំឲ្យព្រាបជាប់យំថ្ងូរ រហូតដល់សព្វថ្ងៃនេះ ។

ព្រាបយំថ្ងូរ ខ្លាំងយ៉ាងនេះ កំផ្អើលទៅដល់សត្វដទៃទៀត មកជួយមើលឈូធរ ។ ក្នុងបណ្តាអ្នកដែលមកជួយនោះ មានសត្វខ្លះកំជួយឈឺឆ្អាល តែមានសត្វខ្លះទៀត ត្រឡប់ជាបញ្ឆោះបន្សោក បន់ផ្តន្ទា ឲ្យព្រាបទៅវិញ ហេតុនេះបានជាមានសម្រែកសត្វប្លែកៗគ្នា តាមភាសា វា គឺខ្លះស្រែកផ្តន្ទា៖

មាន់ ទា ក្អែកស្រែកផ្តន្ទា

-ក្អែកស្រែកថា ៖ " ងាប់ឥឡូវ! ងាប់ឥឡូវ! ងាប់ឥឡូវ! "

(ត្រង់នេះហើយ បានជាក្អែកនៅជាប់ស្រែកថា ៖ ឡូវ!ៗ នៅដល់សព្វថ្ងៃ)

-មាន់ស្រែកថា ៖ " ចប! ចប! " បានន័យថា ឲ្យរកចបមកបំរុងចាំកប់ខ្មោចព្រាបតែម្តងទៅ ព្រោះព្រាបនេះ វានឹងស្លាប់ឥឡូវហើយ ។ នេះជាពាក្យបញ្ឆោះ ព្រោះមាន់ចង់ឲ្យព្រាបស្លាប់ចុះ ។

-ទាស្រែកបន្ថែមតាមក្រោយមាន់ថា៖ “ កាប់! កាប់! កាប់! ” ព្រោះថាបើព្រាបស្លាប់ហើយ មាន់ឲ្យគេរកបបហើយនោះ ត្រូវជីកកប់វាតែម្តងទៅ ។

ក្រៅពីសត្វដែលផ្តន្ទាឲ្យព្រាបស្លាប់ នៅមានសត្វដែលជួយសង្គ្រោះព្រាបច្រើនទៀត ។ នៅពេលនោះ សត្វលលកស្រែកថា៖ “ រកគ្រូ! រកគ្រូ! ” ។ តែសត្វដទៃជំនុំគ្នាថាត្រូវទៅរកមេមត់ ឲ្យមកជួយសង្គ្រោះជីវិតសត្វព្រាបវិញ ប៉ុន្តែរូបមេមត់នោះនៅឆ្ងាយណាស់ ហើយពេលនេះជារដូវវស្សា មានទឹកជោរជន់លិចវាល ល្ហល្ហាច ផង ។ បើនឹងធ្វើដំណើរ ទៅ តោងតែ រក ទូកក្តារ ប្រវាបែវ ទើបបាន ម្ល៉ោះហើយ ពួកសង្គ្រោះទាំងនោះ ម្ទីម្នាស្រែកកកោក កកាករកប្រដាប់ទាំងនេះ លាន់ទ្រហឹង៖

អាអូតស្រែកថា៖ “ ទូក! ទូក! ទូក! ”

មាន់ទឹកស្រែកថា៖ “ ប្រវា! ប្រវា! ប្រវា! ”

ប្រវឹក និងស្មោញ នាំគ្នាបាចទឹកចេញពីទូកឮសូរ ខ្វក់! ខ្វក់! រួចហើយគេក៏ចេញទូក ដឹកនាំទាំងព្រាប ដែលជាអ្នកជំងឺនោះ ប្តោះទៅទីលំនៅមៀមជារូបមេមត់ ។ ទំរាំទៅដល់ ជាពេលពន់ព្រលប់ សត្វមៀមរូបមេមត់យកសត្វទីទុយជាស្នំ គឺជាអ្នកនិយាយលួងលោមរូបមេមត់ ។

បណ្តាសត្វដែលមានសម្រែកផ្សេងៗគ្នា ក៏ប្រជុំគ្នាធ្វើជាវង់ភ្លេងអារក្សមួយវង់ ដើម្បីបញ្ចូនរូបមេមត់នោះ គឺសត្វត្រដុមធ្វើស្គរ សារិកាកែវធ្វើទ្រ ល្ហាចេកធ្វើប៉ី ត្រសេះវាយក្រាប និងទន្សេបជាអ្នកច្រៀង ។

លុះនាំគ្នាធ្វើត្រាប់ភ្លេងបានមួយបទហើយ ទីទុយជាស្នំ ចាប់ផ្តើមសួរឡើងថា៖

ទីទុយពើតពើង! កូនយើងវាយំ!

ទីទុយពើតពើង! កូនយើងវាយំ!

មៀមដែលជារូបមេមត់ ពុំមានស្តីថាអ្វីសោះ រឹតតែបើកភ្នែកធំឡើងៗ លុះទីទុយនៅតែសួរដដែលៗ ពេក ក៏ឆ្លើយតែមួយម៉ាត់ថា៖ មឹម! មឹម! គឺយកទៅឲ្យបោរដោះ ។

ទីទុយសួរទៀត៖

ទីទុយពើតពើង! កូនយើងមិនជា!

ទីទុយពើតពើង! កូនយើងមិនជា!

មៀមស្រែកតបទីទុយថា៖ លៀង! លៀង!

ទិទុយសួរហើយ សួរទៀត ទៀតហើយទៀតសួរ៖

ទីទុយពើតពើង! កូនយើងជាទេ!

ទីទុយពើតពើង! កូនយើងជាទេ!

មៀម នៅតែឆ្លើយតបទិទុយថា៖ លៀង! លៀង!

ពុដូចនោះ គ្រលេងគ្រលោងក៏ស្រែកឡើងថា៖

ជាក៏លៀង! មិនជាក៏លៀង! ជាក៏លៀង! មិនជាក៏លៀង!

លុះចប់ពិធីបញ្ចាន់មេមត់រួចហើយ សត្វទាំងអស់ក៏នាំគ្នាវិលមកកាន់កំពង់ ដើម្បីធ្វើដំណើរត្រឡប់មកកន្លែងខ្លួនវិញ។ មកដល់កំពង់រកទូកពុំឃើញ ក៏បង្អុកហៅរកគ្នា ក្រែងមានអ្នកណាយកទូកទៅ អុំលែង ស្រាប់តែមាន សត្វមួយស្រែកឆ្លើយ ពីត្រើយ ម្ខាងមកថា ៖ “ត្តូកៗ!” ។ គេនាំគ្នាដាក់ឈ្មោះសត្វនោះថា សត្វត្តូកៗ រហូតមកដល់សព្វថ្ងៃ ។

ចំណែកសត្វក្អែក ដែលជាសត្វផ្ដន្ទាឲ្យព្រាបស្លាប់ តែត្រឡប់ជាមិនស្លាប់វិញ ដោយបានទិទុយ មៀម ត្តូក ជួយយកអាសានោះ ក៏ប្រកាន់ស្អប់សត្វទាំងនេះតែកាលណាឃើញសត្វទាំងនេះហើយ តែងតែព្រួតគ្នាដេញចឹកព្យាបាទដាប់រហូតដល់សព្វថ្ងៃនេះ ៕

**២.-សម្រែកប្រេត**

មានមាត់សម្រាប់តែស្រែក

មានភ្នែកសម្រាប់តែយំ

សត្វព្រាបទាំងឡាយ ដែលដេកស៊ី ជុះអាចម៍ដាក់ព្រះ ដាក់ព្រះវិហារ ដាក់ទីសក្ការៈបូជា លុះអស់អាយុសង្ខារពីក្នុងលោកនេះទៅ ក៏បានទៅចាប់កំណើតជាប្រេត ព្រាយ បិសាច អសុរកាយ នរក តិរច្ឆាន ព្រោះវាបានប្រឆាំងនិងមើលងាយព្រះ ។

កើតជាប្រេត ក្នុងភាសាខ្មែរ ប្រែថាមានការលំបាកវេទនា រងទុក្ខវេទនាខ្លោចផ្សាណាស់ ពុំដូចជាពាក្យ ប្រេតក្នុងភាសាបារាំងទេ ដែលត្រូវតែគេគោរពបូជា ព្រោះប្រែថា ស្មើឋានៈគ្នានឹងឋានៈព្រះ ហៅអធិការវត្តផង ។

ក្នុងមួយថ្ងៃៗ នៅឋានក្រោម យមបាលផ្តន្ទាប្រេតទាំងឡាយ តាមទោសដែលបានប្រព្រឹត្ត ដោយសុចរិតយុត្តិធម៌ ល្អត្រឹមត្រូវ ។

ចួនកាល យមបាល យកប្រេត ដែលពីជាតិមុន ធ្លាប់បាន ភរកុហក បោកបញ្ឆោតគេ ឧបមាដូចជាពួក ឈ្មួញ ដួញដូរ សំបូរ សម្បត្តិ ដោយសារ ការគេងប្រវ័ញ្ចផ្គាញ់ផ្គាលគេ ឬឧបមាដូចជាពួកជំណាងរាស្ត្រ ខ្លះ ដែលធ្លាប់តែភូតភររាស្ត្រថា កាលបើខ្លួននឹងបាន ឈ្នះឆ្នោត នឹងលែងបញ្ឆោតរាស្ត្រ តែលុះដល់បានឈ្នះ រាស្ត្រក៏យំយែកស្រែកថ្ងូរ ទ្រហោ តក់ទ្រួង ព្រោះតំណាងខ្លួន ពួនសម្ងំ ពុំព្រមចូល មកជួយលើក ស្នួយដោះស្រាយបញ្ហា ឬស្តារជីវភាព ព្រោះលែងគោរពពាក្យសន្យា ... ទៅដុតមាត់ ទៅកាត់អណ្តាត ។

ចួនកាល យមបាល យកប្រេត ដែលពីជាតិ មុន ធ្លាប់ បាន ផិត ក្បត់ ប្តី-ប្រពន្ធទៅលួចមានសហាយ ... ទៅបង្ខំឲ្យឡើងរកាដែក ស្ដុកស្ដុះ ទៅ ដោយ បន្លា ដ៏ មុត ស្រួច ដោយពួយទម្លុះតូទនឹងជន្ទួញ ឲ្យរហែករបែកឈាមរហេមរហាម យ៉ាងក្រហមប្រាល ។

ចួនកាល យមបាល យកប្រេតដែលពីជាតិមុន ធ្លាប់បាន ប្រព្រឹត្ត អំពើ ពុករលួយ មិនស្លួយ សិលធម៌ មិនជួយ ជ្រោមគ្នីគ្នា រវល់តែទៅតាំពារសត្រូវ ទៅបោះក្នុងទឹកខ្លះឆ្អាតធំៗ កំពុងដាំពុះ ឲ្យរលុះរលាក រលេះរលួយ រលាយខ្លួនប្រាណ ។

ចួនកាល យមបាល យកប្រេតដែលពីជាតិមុនធ្លាប់បាន ដឹកនាំគេ តែពុំបាន ប្រកបដោយផ្លូវប្រសើរ “អរិយមគ្គ“ ដែលនឹងនាំមកនូវដំណើរ មិនចំរុងចំរើន ជឿនលឿនថ្កុំថ្កើង... ព្រោះខ្វះចំណេះដំរេះវិជ្ជា ខ្វះសមត្ថភាព ខ្វះទេព្យកោសល្យ ដោយវិកលពិការ យ៉ាងណា ក៏មិនដឹង? - យកទៅឲ្យទូល ដផ្គាល់វិលធាល់ខែក្បាល - ជាហេតុបណ្តាយឲ្យ ឈាមហូរសស្រាក់ ប្រឡាក់ទាំងដងខ្លួន ជូនទុក្ខជារៀងរាល់ថ្ងៃ ។

តែពួកប្រេតខ្លះ នៅ មានសំណាង ព្រោះកាលបើ យមបាលខឹងជ្រុលនឹងវា ដែលមានទោសដ៏ធ្ងន់ខ្លាំង ហើយក៏តាំងបោះវំលងហួសខ្លះឆ្អាត របូតទៅ ឆ្ងាយ ! ... ។

នៅឯឋានបាតដាល គេឮតែសម្លេង ប្រេតស្រែកថ្ងូរ ទ្រហូរយំជារៀងរាល់ថ្ងៃ ដោយសេចក្តីឈឺផ្សា ពុំមានអ្នកណាអាចទៅ ជួយរំដោះ ឬក៏ទៅរងគ្រោះជំនួសប្រេតបានទេ ។

ប្រេតមួយ មានឈ្មោះហៅថា អាត្រក់ ព្រោះវាបានប្រព្រឹត្តនូវអំពើជ័តម្រក់អស្ចារ្យ ។ ជើងទាំងពីររបស់ប្រេតនោះខ្ពស់បង្គ្រោង ក្បាលវាក្រមោងក្រមែងរលីងដូចបាត្រ មាត់ធំគ្រហូរ រណ្ដៅភ្នែកទាំងគូខូង រូងធំប៉ុនតង យ៉ាងគ្រលួងគួរឲ្យខ្លាច ។

ប្រេតនោះពីជាតិមុនវាជាសត្វព្រាប ដែលបានហើរកន្ទងព្រះវិហារ ដេកលើព្រះវិហារ ស៊ីនៅលើព្រះវិហារ រួចក៏ជុះអាចម៍ ដាក់ព្រះវិហារ លើទីសក្ការៈបូជា និងលើព្រះថែមទៀត ។

ប្រេតនោះ វាមានអំណាច អាចដើរគ្រប់ទិសទី ដើរកន្ទងព្រះវិហារ កាលណាយមបាលលែងវា ឲ្យមកកាន់ឋានកណ្ដាលម្ដងៗ ដើម្បីនឹងផ្សងរកសំណែន នៅវេនបុណ្យភ្ជុំបិណ្ឌ ។ តែវាពុំដែលបានទទួលនូវ អំណោយទានដែលសាច់ញាតិសាវលោហិតរបស់វាទេ ព្រោះសាច់ញាតិវាក៏ជាសត្វព្រាបដូចគ្នា ហើយគ្មានព្រាបមួយណាដែលចេះធ្វើបង្អាន់ និងចេះបង្អុយនំនែក ហើយនិងហើរទៅរកបេះអំពៅ យកមករំលែកប្រគេនព្រះសង្ឃឡើយ ។ ម៉្លោះហើយវាក៏ពុំអាចប្រទេចផ្កាសារ ទៅលើញាតិការបស់វា សូម្បីតែម្នាក់ក៏ទេដែរ! អាត្រក់ គិតតែដើរទៅធក់ បំណីបំណុករបស់គេឯង ដោយតម្រាមកំហែង តាមទំនើងចិត្ត ត្បិតសេចក្ដីស្រេកឃ្លាន ។

ក្មេងក្មាងពុតែឈ្មោះអាត្រក់ ក៏ភ័យស្ទើរលោះព្រលឹងព្រលះ ស្ទុះស្ទះរញីរញ័ររញ៉ីរញ៉ៃ ដោយខ្លាចនូវអំណាចតេជ្ជះដៃរបស់វា ក្រែងលោវាមកទាមទារពន្ធះសាច់ប្របាច់ក ដូចកាលដែលក្មេងបានធ្វើបាបដល់ពួកវា កាលពីជាតិមុន ។

ចាស់ៗ ក៏ពុំដឹងជាគ្រុនរងាយ៉ាងណាដែរ កាលបើគាត់ត្រូវតែជួបនឹងពួកប្រេតនោះ ដោយខានមិនបាន?

តែឪពុកមាខ្ញុំដែលឈ្មោះប្រប គាត់បានប្រាប់ខ្ញុំថា បើប្រេតនៅត្រង់ណាត្រូវតែចេះប្រប ស្របតាមពាក្យចាស់ថា “ប្រាជ្ញពុំស្មើប្រប ទន់ស្លឹកត្រចៀកខ្លប ពុំស្មើឡេមឡឺម”។ ខ្ញុំមានយោបល់ ថាតើឲ្យខ្ញុំធ្វើម្ដេចបាន បើខ្ញុំពុំមែនមានឈ្មោះប្របដូចលោកមា? គាត់ទូន្មានបញ្ជាក់ប្រាប់ខ្ញុំទៀតថា គាត់ពុំមែន ចង់ឲ្យខ្ញុំដើរតួប្របដូចគាត់ទេ ក៏ប៉ុន្តែគាត់ចង់ឲ្យខ្ញុំចេះសម្របសម្រួលគ្រប់កាលៈទេសៈ តាមសភាពការណ៍ ក្នុងការរស់នៅ ជាពិសេសក្នុងការជួបប្រេតព្រាយ បិសាចអសុរិកាយនេះ ព្រោះតាមធម្មតាអ្នកប្រាជ្ញមិន

បេះប្រប គឺមិនមានការប្រស្រ័យនឹងអ្នកធំ ទោះស្លូតសភាពយ៉ាងណាក្តី ក៏ពុំស្មើនឹងអ្នកខ្មៅ ដែលគេជាមនុស្សជិតជិតនឹងអ្នកធំឡើយៗ ម៉្លោះហើយបានជាមាប្របគាត់បោលតម្រុយពាក្យខាងលើនេះ ។ គាត់ពោលបន្ថែមទៀតថា៖ ចូរក្មួយកុំប្រយុទ្ធតស៊ូជាមួយពួកប្រេត បើពួកប្រេតវាទៅត្រង់ទីណា គួរតែក្មួយចៀសចេញពីពួកវា បើបានឆ្ងាយ នោះរឹតតែបានល្អ !

មាប្របគាត់ក៏មានរឿងនិទាន ប្រាប់ខ្ញុំជាច្រើនណាស់ដែរ ជាពិសេស រឿងដែលទាក់ទងនឹងខ្មោចព្រាយ អសុរកាយ ប្រេត បិសាច នេះ ។

រឿងទាក់ទងនឹងប្រេតក៏ត្រូវបានបកសារដោយមាប្រប តាមរឿងដូចតទៅ ៖

**រឿងទាក់ទងនឹង**

**បុណ្យភ្ជុំបិណ្ឌ-បណ្តែតដូនតា**

មានសេចក្តីដំណាលថា មានឈ្មួញសំពៅ ៥០០ ធ្វើដំណើរចេញទៅជួញតាមសមុទ្រ ។ លុះទៅដល់កោះមួយនោះ ជួនជាល្ងាច នឹងធ្វើដំណើរទៅមុខទៀតក៏ស្ទើរ ទើបនាំគ្នាចូលចតសំពៅនៅទីនោះៗ កោះនោះ ជាកោះដាច់ស្រយាល ឥតមានមនុស្សនៅទេ ហើយពេលយប់ តែងតែមានពួកប្រេត នាំគ្នាដើររកស៊ី ។ ពួកប្រេតទាំងនោះ លុះដើរក្រវែលរកអាហារ ឃើញមនុស្សដេកក្នុងសំពៅ ក៏ចាប់មនុស្សកំពុងដេកលក់យកទៅថ្វាយចៅហ្វាយវាខ្លះ គិតនឹងហែកស៊ីខ្លះ ។ ពួកមនុស្សដេកលក់ ដោយសារសំឡេងប្រេតនិយាយគ្នា ក៏ភ្ញាក់ឡើង ភ័យស្លុត យំសោកទ្រហឹង ខំអង្វរករ ដូចម្តេចក៏ពួកវាពុំព្រម ហើយគិតតែពីចាប់នាំទៅប្រគល់ឲ្យចៅហ្វាយនាយវា ។

សម្រែកយំសោកបណ្តោយឲ្យផ្អើលមនុស្សអស់ទាំង៥០០សំពៅ ពេលនោះ នាយសំពៅម្នាក់ ជាអ្នកឈ្លាសវៃ នឹកឃើញថា ទោះបីជាត្រូវស្លាប់ ក៏ត្រូវតែហ៊ានប្រថុយនិយាយតវ៉ាឲ្យអស់ចិត្តសិន មិនត្រូវឲ្យគេផ្តាច់ជីវិតទទេៗឡើយ គិតហើយ ក៏តាំងស្មារតី

អង់អាច និយាយទៅកាន់ស្តេចប្រេត សូមឲ្យលែងពួកខ្លួន តែស្តេចប្រេតនោះឆ្លើយថា៖“ យើងនឹងលែង ពួកឯងទៅវិញ មិនបានទេ ព្រោះពួកយើង ស្រេកឃ្លានណាស់ បើលែងពួកអ្នកឯងទៅ មិនដឹងជាកាលណានឹងបានទៀតទេ ពួកយើងខ្វះអាហារណាស់ ! ” ។

នាយឈ្នួញអង្វរថា៖

សុំលោកលែងពួកយើងទាំងអស់វិញចុះ យើងសន្យាថា នឹងទទួលរកអាហារជូនលោករៀងរាល់ឆ្នាំ លុះត្រាតែអស់ជីវិត បើលោកពិសាយើងទៅនោះ លោកបានឆ្អែតតែមួយគ្រាប៉ុណ្ណោះ អំណើះតទៅ លោកនឹងត្រូវអត់ឃ្លានទៀត បើពួកយើងសន្យានឹងលោកយ៉ាងនេះ តើលោកយកផ្លូវណា? លោកសុខចិត្តពិសារូបយើងឲ្យបានឆ្អែតមួយបំអែត ឬក៏សុខចិត្តទុកជីវិតពួកយើង ដើម្បីឲ្យទៅរកអាហារជូនលោកវិញ? ។

ពួកប្រេត ឮសំណើនៃនាយឈ្នួញដូច្នេះ ក៏គិតគ្នាមួយសន្ទុះ ទើបព្រមដោះលែងពួកឈ្នួញ ហើយផ្តាំថា៖ “ កាលបើពួកអ្នកបានទៅដល់ស្រុកទេសខ្លួនហើយ កាលណាមានខ្យល់ដំនោរធ្លាក់មកពីទិសឯជើង អ្នកទាំងអស់គ្នា ត្រូវធ្វើក្បូនផ្ទុកធញ្ញជាតិ និងអាហារគ្រប់យ៉ាង មានលាជ សណ្តែក ល្ង ដូង អំបុក បេក ជាដើម បណ្តែតតាមទឹក មកឲ្យយើងចុះ មិនបាច់នាំមកផ្ទាល់ទេ ដំនោរខ្យល់នឹងបញ្ជូនមកដល់យើងហើយ ” ។

ឮតែប៉ុណ្ណោះពួកអ្នកសំពៅ អររកអ្វីប្រៀបពុំបាន ហើយក៏នាំគ្នាចុះសំពៅរបោករបល់ខ្សៀវខ្សារ បើកចេញផុតពីនោះយ៉ាងប្រញាប់ ។ លុះទៅដល់ភូមិស្រុក ជួបជុំគ្រួសារហើយ ត្រូវនឹងពេលជិតដល់រដូវភ្ជុំ ដែលទឹកឡើងជាលំដាប់ផង អ្នកដែលបានសន្យានឹងប្រេតទាំងនោះ ក៏នាំគ្នាធ្វើនំនែក រកបេកអំពៅ លាជ ស្រូវ អង្ករ ផ្លែឈើដែលមានក្នុងរដូវនោះ ធ្វើពោងពាង ហើយដាក់បណ្តែតបញ្ជូនទៅឲ្យប្រេតតាមខ្សែទឹករាល់ៗឆ្នាំ ។

មនុស្សជាន់ដើម កាន់ពាក្យសច្ចៈល្អណាស់ បើនិយាយសន្យាថាដូចម្តេចហើយ មិនហ៊ានបំពានទេ ។

ចំណេរមកអ្នកស្រុកក៏នាំគ្នាធ្វើតៗមក ទៅជាទំនៀមទំលាប់ ដោយយល់ថា “ ធ្វើបុណ្យបណ្តែតស្រូវអង្ករទៅឱ្យ ដូនតាដែលទៅកើតជាប្រេត ឋិតនៅឯស្រុកទន្លេស្ងួត កន្ទួតមួយដើម” នោះវិញ ។

រៀងរាល់ពេល យប់ព្រលប់ មាប្រប រមែង ហៅកូនក្មួយ ទៅ ប្របាច់ គត់ឲ្យគាត់ ព្រោះពេញ មួយថ្ងៃ គាត់ធ្វើបម្ការ មានការ ហត់នឿយ រោយ ចុកស្រពន់...។ គាត់ តែងតែ និទានរឿង ពីនេះពីនោះ ឲ្យកូនក្មួយស្តាប់ ដើម្បី បំបាត់ ការអផ្សុក ម្យ៉ាង និង ដើម្បីកុំឲ្យងងុយដេក ម្យ៉ាងទៀត ។ គាត់ជ្រើសរើស តែរឿងណា ដែលនាំឲ្យកូនក្មួយ ខ្លាច ហើយខិតចូលទៅជិតគាត់ ដោយដៃនៅប្របាច់គក់គាត់រហូត ។ រឿងមួយទៀត ដែលខ្ញុំនៅចាំបាន គឺរឿង ដើមចេកជ្វា និងដើមបាយម៉ាត ។ ខ្ញុំ ប្រុងស្តាប់ រឿងនេះ ដំបូងខ្ញុំស្មានថាជារឿងធម្មតា តែដល់បានស្តាប់យូរទៅ ក៏យល់ថាជារឿងមួយ គួរ ឲ្យព្រឺក្បាលខ្លាក!

**រឿងដើមចេកជ្វា**

**និង**

**ដើមបាយម៉ាត**

ចាស់បុរាណខ្មែរយើង ច្រើនជឿហើយហាមប្រាមកូនចៅ មិនឲ្យដាំដើមចេកជ្វា នៅជិតសំយាបផ្ទះ ព្រោះគេយល់ឃើញថា វាដាក់ម្ចាស់ផ្ទះ ។ បានជាមានជំនឿយ៉ាងនេះ ដោយមានរឿងដំណាល ដូចតទៅ ៖

ជាយូរអង្វែងណាស់មកហើយ មានគ្រួសារមួយជាអ្នកទិទ័លក្រ ប្រកបរបររកស៊ី ជាកសិករ ។ ក្នុងពេលមួយ ដែលជារដូវរាំងបុស ឥតមានភ្លៀងធ្វើស្រែ បុរសប្តីក៏លា ប្រពន្ធទៅរកស៊ីឈ្នួលគេ នៅស្រុកឆ្ងាយ ។ ក្រោយដែលបុរសនេះចេញផុតទៅ ស្រុក ក៏កើតជំងឺអហិតវាតរោគ រាតត្បាតពាសពេញ បណ្តាលឲ្យអ្នកភូមិទាំងមូល ភ័យជ្រួល ប្របល់យ៉ាងសំបើម ។ មុនដំបូង ជំងឺនោះបណ្តាលឡើងអំពីសត្វតូចតាច លុះយូរបន្តិច ទៅ ក៏រាលដាលដល់សត្វធំៗ រហូតដល់ជីវិតមនុស្សក្នុងភូមិផង គ្មាននរណាអាចជួយ នរណាបានឡើយ ។ ផ្ទះនិមួយៗ ស្ងាត់ឈឹង ពេលយប់គេឮតែសំឡេងឆ្កែលូ និងពន្លឺភ្លើង ប្រទីបផ្លុងៗ ត្រង់នេះមួយ ត្រង់នោះមួយ គួរឲ្យព្រឺក្បាលពន់ពេក ។

នៅភូមិខ្វះ ដែលរោគនេះមិនទាន់រាលដាលទៅដល់ អ្នកនិគមជនបទទាំងនោះ ក៏ពុំហ៊ានដើរស្វែងរកប្រកបកិច្ចការរហេតរហូត ដូចប្រក្រតីឡើយ មនុស្សទាំងនោះ មានកិរិយាស្ងប់ស្ងៀម មានទឹកមុខក្រៀមក្រំ ស្រពាប់ស្រពោនជានិច្ច និយាយរកគ្នាទៅវិញទៅមក ដោយខ្សឹបខ្សៀវ មិនហ៊ាននិយាយគ្នាកោកកាក ឬនឹកឈ្មោះដែលកើតជំងឺចង្រៃទាំងនោះផងទេ។

មានថ្ងៃមួយ នៅពេលដែលជំងឺ កំពុងតែបង្កើនឥទ្ធិពលយ៉ាងខ្លាំង ស្រាប់តែមានទាយកម្នាក់មកនិមន្តព្រះសង្ឃ ៤ អង្គ ទៅបំរើនព្រះបរិត្ត នៅផ្ទះរបស់ខ្លួន ។ លុះដល់ពេលកំណត់ ទាយកនោះក៏មកទទួល ព្រះថេរៈចៅអាវាស ព្រមទាំង ភិក្ខុ៣រូបទៀត និមន្តទៅដល់ផ្ទះឧបាសកនោះ ឃើញមានភ្ញៀវយ៉ាងច្រើន ។ គេក៏និមន្តព្រះសង្ឃទាំ៤ អង្គ ឡើងលើផ្ទះ គង់លើអាសនៈយ៉ាងសមគួរ ហើយប្រគេនភេសជ្ជៈ តែ ស្ករ បារី តាមទំនៀម ។ បន្ទាប់មក គេនាំគ្នានមស្ការព្រះរតនត្រ័យ រួចអារាធនាព្រះសង្ឃបំរើនព្រះបរិត្ត ប៉ុន្តែគេទូលលោកថា៖ “សូមលោកម្ចាស់ កុំសូត្រធម៌ករណិយ៍ សូមនិមន្តសូត្ររំលងទៅ វិរូបក្ខេ តែម្តងទៅ ដើម្បីកុំឲ្យយូរពេល ។ ព្រះសង្ឃចាប់ផ្តើមចំរើព្រះបរិត្ត តាំងអំពីដើមរៀងទៅ លុះដល់ ធម៌ករណិយ៍ លោកក៏ចោលទៅសូត្រ វិរូបក្ខេ តាមពាក្យទាយកបវារណាសុំតែម្តង ។ ក្នុងពេលនោះ លោកសង្កេតឃើញទាយកទាយិកាសប្បាយរីករាយ សើចញញឹម ញញែមក្របួចមាត់ក្របួចក គ្រប់ៗគ្នា ។ ព្រះថេរៈដើមអាសន៍នឹកឆ្ងល់ថា៖ គេសុំកុំឲ្យសូត្រធម៌ករណីយ៍ សុំឲ្យផ្លោះទៅសូត្រវិរូបក្ខេតែម្តង ឥឡូវសូត្រវិរូបក្ខេទៅស្រាប់តែគេនាំគ្នាសប្បាយ បែបដូចជាប្លែក។ ព្រះថេរៈនឹកអៀនក្នុងព្រះទ័យណាស់ ខ្លាចក្រែងគេរិះគន់ថា លោកសូត្រខុស ទើបត្រឡប់មកចាប់សូត្រធម៌ករណីយ៍វិញ។

លោកទើបតែនឹងចាប់សូត្រ បាន៣-៤ព្រះឱស្ឋ ស្រាប់តែ ទាយក ទាយិកា នាំគ្នាដកខ្លួនថយបន្តិចម្តងៗ រហូតដល់អស់រលីង ស្ងាត់សូន្យឈឹង។ ភ្លើងក៏រលត់ភ្លឹប ផ្ទះដែលព្រះសង្ឃឡើងទៅនោះ ត្រឡប់ទៅជាគុម្ពឫស្សី យ៉ាងញាតស្បាត បារី តែ ស្ករ ទៅជាដុំធ្យូង ដីខ្សាច់ និងកំណាត់ឈើអស់ ។ ទើបព្រះសង្ឃភ្ញាក់ថា ជាបិសាចក្លែងខ្លួនធ្វើជា

មនុស្ស ៗ ទំរាំតែព្រះភិក្ខុផងគ្នា នៅឯវត្តដឹងថា លោកគ្រូដាប់នៅបុងឫស្សី លោកគ្រូនិងព្រះសង្ឃ៣អង្គទៀត ត្រូវអត់បង្ហាន់២-៣ថ្ងៃៗ

ដោយហេតុហ្នឹងហើយ ទើបចាស់បុរាណលោកថា ៖ ធម៌ករណីយ៍ នេះធ្វើឲ្យខ្មោចខ្លាចណាស់ ៗ ឯ ធម៌វិបត្តេ ធ្វើឲ្យខ្មោចសប្បាយទៅវិញ ៗ កាលណាស្រុកមិនសូវស្រួល ដោយមានកើតជំងឺ ជង្គាត់ផ្សេងៗ មានអាសន្នរោគ អុតជាដើមនោះ គេតែងនិមន្តព្រះសង្ឃបំរើនព្រះបរិត្ត ហើយសុំឲ្យសូត្រធម៌ករណីយ៍ នេះ ឲ្យបាន៧-៨ចប់ ហើយហាម ផ្តាច់ មិនឲ្យព្រះសង្ឃសូត្រ ធម៌វិបត្តេ ឡើយ ដោយមានជំនឿតាមរឿងដូចបានរៀបរាប់ខាងលើនេះ ៗ

មយ៉ាងទៀត បុរាណមានជំនឿថា បើយើងដើរទៅណាមកណាយប់ ហើយបើមានព្រឺរោម ព្រឺស្បែកត្រូវឲ្យសូត្រធម៌ករណីយ៍នេះដែរ ដោយសំអាងថាខ្មោចមិនលង ៗ ”

និយាយពីបុរសដែលទៅរកស៊ីស្រុកឆ្ងាយនោះ ក្រោយដែល បានទៅរកស៊ី មានលុយ កាក់ល្មម ត្រឡប់មកលំនៅ ម្តងហើយ ក៏វិល ត្រឡប់មកស្រុកកំណើតវិញ ៗ មកដល់កណ្តាលផ្លូវ គេប្រាប់ថា៖

“អ្នកឯងទៅមិនទាន់បានទេ ព្រោះភូមិអ្នកឯងនោះ កើតជំងឺអាសន្នរោគ ច្រើនណាស់ មនុស្សអ្នកភូមិស្លាប់គ្មាននរណាកប់នរណាទេ ឯប្រពន្ធកូនរបស់អ្នកឯង ក៏ប្រហែលជាស្លាប់ទៅហើយ ឬយ៉ាងណា ក៏មិនដឹង ព្រោះភូមិដទៃ ឥតមាននរណាម្នាក់ហ៊ានចូលទៅទេ ៗ ”

បុរសនោះ ដោយសេចក្តីនឹកប្រពន្ធ–កូនខ្លាំងពេក ក៏ បេះតែបបេសចូលទៅ គាត់ខំធ្វើដំណើរទៅទាំងយប់ ហើយទាំងសស្ងើតសស្ងក់ផង ៗ លុះទៅជិតដល់លំនៅខ្លួន មើលទៅឃើញភ្លើងផ្ទុងៗ គ្រប់ផ្ទះ ដូចប្រក្រតី គាត់ត្រេកអរណាស់ ហើយនឹកខឹងនឹងអ្នកស្រុក ដែលប្រាប់ពីកណ្តាលផ្លូវ ៖ គេនិយាយកុហកខ្លួន ៗ ប៉ុន្តែនៅតាមផ្លូវទៅកាន់ផ្ទះគាត់ គាត់មានសង្ស័យដែរ ចំពោះសភាពស្ងប់ស្ងាត់ពិធម្មតា តែគាត់សន្និដ្ឋានថាប្រហែលជាស្រុកមិនស្រួលមែន ទើបស្ងាត់យ៉ាងនេះ ៗ លុះទៅដល់ទ្វាររបងផ្ទះ ក៏ស្រែកហៅប្រពន្ធ ពេលនោះគាត់ឃើញស្រីម្នាក់ ដែលគាត់ស្គាល់ច្បាស់ ថាជាប្រពន្ធរបស់គាត់ រត់មកទទួលយ៉ាងរាក់ទាក់នឹងគាត់ដូចធម្មតា គ្មានអ្វីគួរឲ្យសង្ស័យសោះ ៗ

នាងនោះ ខំប្រញឹបប្រញាប់ ទៅបន្ទាត់ភ្លើងដាំបាយ ឲ្យប្ដីបរិភោគ ប៉ុន្តែនាងហាមប្ដីមិនឲ្យ ចូលទៅ ក្នុងបន្ទប់នាងដេកទេ ឲ្យ គាត់សំរាក នៅ ខាងក្រៅ សិន ហើយ ។ ប្ដីនឹកឆ្ងល់នឹងឥរិយាបថ ដ៏ចម្លែក របស់ភរិយា ណាស់ ដោយគាត់សង្កេតឃើញភ្នែកនាងធំៗលៀនៗ បែបក្រហម ហើយក្រឡឹបក្រឡាប់ ខុសពីធម្មតា ថែមទាំងធុំក្លិនគំរង់សាកសពបក់ចេញពីបន្ទប់ ដេក មក ម្ដងៗ ផង គាត់ចង់ដឹង ថា តើ មានអ្វី នៅ ក្នុង បន្ទប់ដេក នោះ បានជានាងឃាត់ មិនឲ្យ ចូល? គិតសព្វគ្រប់ទៅ ក៏ចេះតែអង្គុយសង្កេតកិរិយា របស់ប្រពន្ធ បន្តិចមកឃើញ លៀនអណ្ដាតយ៉ាងវែង កេវយកវែក ដែលរបូតពីដៃធ្លាក់ទៅដីមកវិញ ។ ប្ដីដែលចេះតែសំឡឹង អាកប្បកិរិយាប្រពន្ធ កាល បើឃើញដូច្នោះ ដឹងថា មិនមែន ជាប្រពន្ធខ្លួនពិតប្រាកដទេ គឺ ប្បាស់ជាពួកបិសាចក្លែងភេទ ហើយទើបនឹក ឃើញដល់ រឿង ដែលគេនិយាយ ប្រាប់ ពី កណ្ដាលផ្លូវថា មានពួកបិសាច ផ្សំបាប លោកសង្ឃ ដូចរៀបរាប់មកហើយនោះភ្លាម ក៏លប ទៅ វែកមុងក្នុងបន្ទប់ដេកប្រពន្ធខ្លួនមើល ឃើញខ្មោចប្រពន្ធកូន ខ្លួន ស្លាប់ស្អុយរលួយ ជន្លូវ រុកជ្រិចៗ ។

គាត់ថយ ចេញមកវិញ ហើយគិតរកមធ្យោបាយ ដើម្បីរំដោះខ្លួន អំពី កណ្ដាប់ដៃមេបិសាច នេះ ទើបគាត់ និយាយ ទៅ កាន់នាងនោះថា ៖ ឯងដាំបាយឲ្យឆ្អិនធាប់វ៉ិ គ្នា ទៅនោម នៅ ចុងរាន ក្រៅ ផ្ទះឯណោះ មួយភ្លែត ។ ថាហើយ គាត់ក៏ ទៅ បោះក្អមទឹកមួយ ដែលនៅ ក្បែរនោះ បង្ហូរ ទៅដី ឮដូច មនុស្ស នោមមែន ។ បោះរួច គាត់លប ចុះ រត់បាតជើងសព្រាតតម្រង់ទៅរកអារាមមួយ ដែលមានលោកគ្រូ១ អង្គ ចេះមន្តអាគម គាថាពូកែខាងការពារ ខ្មោចបិសាច និងអាបធ្មប់ ។

ចំណែកនាងបិសាច ឮសូរប្ដីនោមយូរពេក ក៏នឹកឆ្ងល់ ក៏តាម ទៅមើល មិនឃើញប្ដី ក៏មិតរត់តាមក្រោយយ៉ាងលឿន ដល់ពាក់កណ្ដាលផ្លូវ ឃើញប្ដី ។ ចំណែកឯប្ដី រត់មិនទាន់បានប៉ុន្មាន ងាក ក្រោយ ឃើញខ្មោចដេញតាម ដឹងខ្លួនថា មើលទៅ ស្លុះមិនរួចអំពីកណ្ដាប់ដៃបិសាច ក៏រត់ ឡើងដើមបាយម៉ាត ១ ដើម ដែលនៅ ក្បែរនោះ ដោយខំប្រឹងឡើង រហូតដល់របូត ខោ របូត អាវអស់ ។ នាងបិសាច មិនហ៊ាន ទៅ ជិត ដើមនោះសោះ ចេះតែដើរក្រឡឹងៗ ក្បែរៗ ហើយស្រែកហៅ ប្ដី ឲ្យ ចុះមក ថា ៖

“អ្នកប្រុស មុខស្អាត លើដើមបាយម៉ាត អញ្ជើញ ចុះមក!

ឈរទ្រាំដល់ណា អត់អាវអត់ខោ អញ្ជើញចុះមក៍!

ចាំអូនរើសជូន! ”។

*បុរស នោះដឹងថា នាង បិសាចនេះ ពិតជា ខ្លាច ដើមបាយម៉ាត នេះហើយ បាន ជាមិនហ៊ានមកជិតអញ សោះ ក៏កាប់មែកបាយម៉ាត១មែក លីដើរ ននលគក សំដៅ ទៅវត្តទៅ ឯនាងបិសាច ពិតមែនតែមិនហ៊ាន ទៅ ជិតបុរសប្តី ដោយ ខ្លាច ដើមបាយម៉ាត មែនតែនាងនៅតែដើរតាមពីក្រោយរហូត ។ បុរសទៅដល់វត្ត ស្ទុះចូល ទៅកណ្តាលជំនុំសង្ឃដែលកំពុងធ្វើឧបោសថកម្ម នៅក្នុងព្រះវិហារ ហើយពិតពុទ្ធដីកាព្រះសង្ឃតាមដំណើរ ។ ពេលនោះ លោកគ្រូ ដែលពូកែ ខាងមន្តអាគម គាថា ក៏នាំបុរស ទៅ ក្នុងកុដិរបស់លោក ហើយសូត្រអាគមគាថា ព័ទ្ធសីមា យ៉ាងស្វាហាប់ ។ ឯនាងបិសាច ក៏មិនទៅណាឆ្ងាយ អំពីកុដិព្រះសង្ឃនោះទេ ។ ពិតមែនតែនាងចូលទៅក្នុងកុដិលោក តាមប្តីរបស់នាងមិនបាន ដោយរបាំងនៃមន្តអាគមគាថា ប៉ុន្តែ នាងចេះតែក្រវែលរកមធ្យោបាយគ្រប់បែបយ៉ាង ដើម្បីចូលទៅតាមប្តី ។*

*នៅក្បែរកុដិព្រះថេរៈអង្គនោះ មានដើមចេកជ្វា១ ដើម ដែល មាន ធាងដុះ ចូលទៅត្រង់បង្អួច កុដិ ។ ទោះបីមន្តអាគមរបស់លោក ជំពូកែយ៉ាងណា ក៏មិនអាចទប់ ឈ្នះនឹង ដើមចេកជ្វា នោះដែរ ។ លោកព័ទ្ធ សីមា បានតែត្រង់កន្លែងណា ដែលធាងចេកជ្វាមិនទៅប៉ះនឹងសំយ៉ាបកុដិប៉ុណ្ណោះ ចំពោះ១ ភាគតូចនៃកុដិរបស់លោក ដែលធាងចេកជ្វា ទៅប៉ះនោះ នៅចន្លោះ ជាឱកាស ដ៏ប្រសើរ ដល់នាងបិសាច នាងបិសាចក៏ឡើងតាមដើមចេកជ្វា ហើយសួរតាម ធាង ចេកនោះ ឆ្វេងចូលទៅក្នុងកុដិរបស់លោក កាប់ក ប្តីរបស់ខ្លួន សម្លាប់ក្នុងពេលនោះទៅ ។*

*ព្រោះហេតុដូចមាន រឿងនិទាន មកនេះហើយ ទើបបុរាណខ្មែរ យើងនិយមជំនឿនេះ ហាមប្រាមកូនចៅ មិនឲ្យដាំដើមចេកជ្វា នៅជាប់នឹងសំយ៉ាបផ្ទះ គេថាវាជាក់ខ្លួន ។ ឯដើមបាយម៉ាត ក៏បានជាឱសថសំរាប់ ការពារ មួយមុខយ៉ាងពូកែ ចំពោះខ្មោចព្រាយបិសាច និងអាបធ្មប់ ជាប់រហូតមកដល់សព្វថ្ងៃនេះ ។៚*

*ចេកជ្វា ជាចេកម្យ៉ាង មានស្លឹកក្រាស់ ផ្លែស្រដៀងនិងផ្លែចេកស្នាប់មុខ គឺរាងទ្រនុងស្រឡូន ទ្រលុកធំជាងផ្លែចេកណាំវ៉ា តែពុំឆ្ងាញ់ពិសាទេនៅពេលទុំ ព្រោះក្នុង*

សាច់វា មានសុទ្ធតែគ្រាប់ ។ គេច្រើន យកផ្លែបេកជ្វា ដែលនៅខ្ចី ទៅធ្វើជ្រក់ ដែលអ្នកបាត់ដំបងហៅថា “ សៀមប្រៀម ” សំរាប់ផ្លាប់ នឹងត្រីអាំង យ៉ាងស្រស់មាត់ ។

ស្លឹកបេក ជា គេពុំយកទៅប្រើការទេ ។

ដើមបេកជ្វា គេយកទៅធ្វើជាសម្ភូរដើមបេក យ៉ាងផុយរអ៊ុះ មានឱជារសឆ្ងាញ់ ជាងដើមបេកណាំវ៉ា ។ កាលពីដើម គេ ពុំ ដែល ស្ងូម្ភូរដើមបេកណាំវ៉ាទេ គេប្រើតែដើមបេកជ្វា រឺដើមបេកណាំវ៉ា គេយកទៅហាន់ឲ្យស្តើង លាយនឹងកន្ទក់សំរាប់ធ្វើបាយជ្រូក ។ ដល់ថ្ងៃក្រោយ គ្មានដើមបេកជ្វា ទើបគេយក ដើមបេកណាំវ៉ាមកជំនួស ក្នុងការស្ងូស្លុកនេះ ។

រីឯដើមបាយម៉ាត គេច្រើន ដាំនៅតាមវត្ត និង នៅផ្ទះគ្រូមន្តអាគម ខ្លះ បំណែកនៅផ្ទះអ្នកស្រុកពុំសូវ មានដាំដើមបាយម៉ាតទេ ទំនងជានៅវត្ត សម្បូរទៅដោយ ធាតុ ខ្មោច រូប ព្រះ សង្ឃក៏ ត្រូវ ឧបាសក ឧបាសិកា និមន្តទៅធ្វើបុណ្យខ្មោចជាញឹកញាប់ ហើយគ្រូមន្តអាគម ក៏ត្រូវទៅជួយសង្គ្រោះ អ្នកស្រុក ក៏មិនស្ទើរ ដែរ ទើបបានជា មាន ការ ភ័យ ខ្លាចខ្មោច មកតាមលង ក៏ខំប្រឹង ដាំដើមបាយម៉ាតនេះសំរាប់ការពារព្រះអង្គ និងការពារខ្លួន។

ឥឡូវ រលោះពាយ រលាយអស់ ទាំង ដើម បេកជ្វា ទាំងដើម បាយម៉ាត តើនឹងបានផ្លែបេកអ្វីយកមកធ្វើជ្រក់ឬ”សៀមប្រៀម ” ជំនួសផ្លែបេកជ្វា ឲ្យបានឆ្ងាញ់ពិសា គួរស្រក់ទឹកមាត់? - តើនឹងបានដើមឈើអ្វី យកមកសំរាប់ការពារខ្មោច ព្រាយបិសាច ជំនួសដើមបាយម៉ាត?

បើស្រែអស់ខ្មុក ឬ បើខ្មែរអស់សុខ នឹងត្រូវអ្នកស្រុកឬអ្នកស្រែប្រើជាពាក្យ គ្រលាស់ថា បើស្រុកអស់ខ្មែរ ឬ បើខ្មុកអស់សែ តើនឹងមាន សាសន៍ណា ឬក៏សែណា ទៅវិញ សំរាប់មកជំនួសខ្មែរ ឬក៏មកជំនួសសែ ដែលធ្លាប់តែថែទាំខ្មែរឲ្យបានសុខ?

គួរតែជនរួម ជាតិ និងញាតិខេមរា ប្រកបដោយខន្តិ ប្រណិមេត្តា យោគយល់នូវគ្រប់យោបល់ ដ៏ខ្សត់ខ្សោយ ដែលបណ្តែតបណ្តោយ ឲ្យព្រាត់ប្រាស និរាស គ្នីគ្នា កំព្រាអនាថា យ៉ាងកម្សត់ខ្លោចផ្សា យ៉ាងនេះ!

តម្រិះយល់ឃើញត្រូវ តម្រិះត្រិះរិះត្រូវ

| | |
|---|---|
| វាចាសម្តីត្រូវ | អនុវត្តន៍ការងារត្រូវ |
| ប្រតិបត្តិការចិញ្ចឹមជីវិតត្រូវ | ឧស្សហ៍ ព្យាយាមត្រូវ |
| រំឭកការរឭកត្រូវ | ស្មិង ស្មាធិ៍ សង្ឃាតសមាធិត្រូវ |

ត្រូវទាំងប្រាំបី ត្រូវចាត់ទុកជាផ្លូវប្រសើរ  ស្របតាមដំណើរអរិយមគ្គ។

ចប់ភាគ១